# របាយការណ៍ប្រចាំខែមេសា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ

## I. ស្ថានភាពការងាររបស់មន្ទីរ ÷

### 1. ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ ÷

- ❖ ស្ថានភាពបុគ្គលិកមន្ត្រីរាជការក្នុងមន្ទីរ

ការងារគ្រប់គ្រងនិងដឹកនាំមន្ទីរមានថ្នាក់ដឹកនាំចំនួន ៣ រូប (ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០២ រូប) និងមានការិយាល័យជំនាញចំនួន ១០ ការិយាល័យ ÷

១- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
២- ការិយាល័យផែនការ-ស្ថិតិ
៣- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
៤- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ
៥- ការិយាល័យអភិវឌ្ឍន៍សហគមន៍
៦- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ
៧- ការិយាល័យថែទាំសុខភាពជនបទ
៨- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
៩- ការិយាល័យផ្លូវជនបទ
១០- ការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចំនួន ០៧ និងក្រុងចំនួន ០១។

#### 1.1. ចំនួនមន្ត្រីរាជការ

| | |
|---|---|
| – សរុប | ÷ ២១នាក់ |
| – ប្រុស | ÷ ១៨នាក់ |
| – ស្រី | ÷ ០៤នាក់ |
| – ចំនួនប្រពន្ធមន្ត្រីរាជការ | ÷ ១២ នាក់ |
| – ចំនួនកូន | ÷ ២២ នាក់ |
| – អវត្តមាន | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចូល | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចេញ | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការក្រេបខ័ណ្ឌថ្មី | ÷ គ្មាន |

- ចំនួនមន្ត្រីរាជការបានតំឡើងប្រាក់បំណាច់មុខងារ ÷ គ្មាន
- ចំនួនមន្ត្រីរាជការបានតំឡើងឋានៈ ÷ គ្មាន
- ចំនួនមន្ត្រីរាជការចូលនិវត្តន៍ ÷ គ្មាន
- ចំនួនបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកបណ្តែត ÷ គ្មាន
- ចំនួនមន្ត្រីរាជការដែលទៅបំពេញបេសកកម្មនៅបរទេស ÷ គ្មាន
- ចំនួនមន្ត្រីរាជការសហការជាមួយកម្មវិធី និងជាដៃគូអង្គការនានា ÷០៦នាក់

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | សហការជាមួយអង្គការ ឬកម្មវិធី |
|---|---|---|---|---|
| ១ | សេង សារី | ប | ប្រធានមន្ទីរ | -គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ២ | ម៉ប់ ធីរិត | ប | អនុប្រធានមន្ទីរ | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៣ | ឈុន ប៊ុនថេង | ប | ប្រធានការិយាល័យ | គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម(ADB) |
| ៤ | ញាណ គង់ | ប | មន្ត្រី | - គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទាន បន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៥ | ឃិត សុធារ៉ា | ប | មន្ត្រី | គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម(ADB) |
| ៦ | ឆាយ សុវណ្ណា | ស | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |

### 1.2. ការងារលិខិតចេញ-ចូល

បានធ្វើចរាចរលិខិតស្នាម ក្នុងនោះមាន÷

- មន្ទីរបានចេញលិខិតបេសកកម្មចំនួន ២១ច្បាប់
- មន្ទីរបានចេញលិខិតទៅស្ថាប័ននានា និងក្នុងមន្ទីរចំនួន ១៦ច្បាប់
- បានទទួលលិខិតចូលពីគ្រប់ស្ថាប័ននានាចំនួន ១៦ច្បាប់
- លិខិតផ្សេងៗចំនួន ០២ច្បាប់។

### 1.3. ការងាររដ្ឋបាល និងបុគ្គលិក

- បានរៀបលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកផ្សេងៗជូនមន្ត្រីរាជការចេញដោយមន្ទីរចំនួន ÷ ០ ច្បាប់
- បានចូលរួមប្រជុំក្រៅខេត្តចំនួន ÷០៣លើក
- បានចូលរួមប្រជុំក្នុងខេត្តចំនួន ÷១២លើក

- បានចូលរួមប្រជុំផ្ទៃក្នុងមន្ទីរចំនួន ÷០២លើក

1.4. **ការងារបៀវត្ស និងពលកម្ម**

- បានរៀបចំប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ២០១៥
- បានរៀបចំបៀវត្សជូនមន្ត្រីរាជការថ្នាក់មន្ទីរប្រចាំខែនីមួយៗ
- ធ្វើរបាយការណ៍បៀវត្សមន្ត្រីរាជការទៅធនាគារអេស៊ីលីដាភីអិលស៊ី ACLEDA PLC
- បានរៀបចំប្រាក់ឧបត្ថម្ភមន្ត្រីរាជការដែលបានចូលនិវត្តន៍ចំនួន ០១នាក់។

2. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ**

+ **ប្រភពថវិការដ្ឋផ្តល់**

- **ថវិកាអនុម័តឆ្នាំ២០១៥ = ៤៤០.៥០០.០០០៛០០**
  - ប្រាក់ជំពូក ៦០ = ៧០.០០០.០០០៛០០
  - ប្រាក់ជំពូក ៦១ = ១៧១.៥០០.០០០៛០០
  - ប្រាក់ជំពូក ៦៤ = ១៩៨.០០០.០០០៛០០
  - ប្រាក់ជំពូក ៦៣ = ១.០០០.០០០៛០០
- **ថវិកាចំណាយសម្រាប់ខែមេសា ឆ្នាំ២០១៥ = ៤០.០០០.៣៨០៛០០**
  - ប្រាក់ជំពូក ៦១ = ៤.៦១៤.០០០៛០០
  - ប្រាក់ជំពូក ៦៤ = ៣៥.៣៨៦.៣៨០៛០០
  - ប្រាក់ជំពូក ៦៣ = ០០៛០០

- ចូលរួមប្រជុំ ស្តីពីការបង្កើតក្រុមលទ្ធកម្ម របស់អង្គភាពចាយថវិកាកម្មវិធី នៅសាលប្រជុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

3. **ការងារផែនការ និងស្ថិតិ ÷**

- ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៥ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដោយប្រើ ប្រាស់ប្រព័ន្ធកុំព្យូទ័រ (M&E Computertzed System)។

4. **ការងារអធិការកិច្ច និង សវនកម្ម÷**

- គ្មានសកម្មភាព

5. **ការងារទំនាក់ទំនងសាធារណៈ**:

- ថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៥ បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ ២០១៤ - ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ជាមួយអង្គការមិនមែនរដ្ឋាភិបាលនៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាពឯកឧត្តម ហាប់ អូម៉ាលី អនុរដ្ឋលេខាធិការ និងជាប្រធានក្រុមការងារទទួល

បន្ទុកអង្គការមិនមែនរដ្ឋាភិបាល របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានការអញ្ជើញចូលរួម ពីអ្នកទទួលបន្ទុកសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល ប្រចាំមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្ត និងអង្គការដៃគូអភិវឌ្ឍន៍លើវិស័យទឹកស្អាត និងអនាម័យជនបទ សរុប ប្រមាណ ៥៦នាក់

- ថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៥ ចូលរួមវិភាគទានក្នុងការរៀបចំកម្មវិធីប្រណាំងទូកងខ្នាត អន្តរជាតិជាលក្ខណៈ មិត្តភាពរវាងខេត្តព្រះវិហារ-ចម្ប៉ាសាក់ នៅស្រុកឆែប ខេត្តព្រះវិហារ
- ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៥ ចូលរួមក្នុងពិធីចុះសួរសុខទុក្ខកងកម្លាំងតាមព្រំដែនចំនួន ០២ កន្លែងស្ថិតនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត និងតំបន់ប្រតិបត្តិការសឹករងព្រះវិហារ ក្នុងភូមិអានសេះ ឃុំជាំ ក្សាន្តស្រុកជាំក្សាន្ត ក្រោមអធិបតីភាព ឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលនៃ គណៈអភិបាលខេត្តព្រះវិហារ។

## II. សកម្មភាពការងារតាមវិស័យ ÷

### 1. សកម្មភាពផ្លូវជនបទ

- ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៥ ចូលរួមប្រជុំក្នុងពិធីផ្សព្វផ្សាយស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក រៀបចំឡើងដោយ មន្ទីរសាធារណការក្រោមអធិបតីភាព **ឯកឧត្តម អ៊ុំ ម៉ារ៉ា** អភិបាល នៃ គណៈអភិបាលខេត្តព្រះវិហារ។

### 2. ការងារផ្គត់ផ្គង់ទឹកជនបទ

- នៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១៥ នៅភូមិកក់កន្ទុង ឃុំស្រយ៉ង់បានប្រារព្ធរៀបចំពិធីទិវាទឹក ពិភពលោក ក្រោមប្រធានបទ ÷ ទឹកនិងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ក្រោម អធិបតីភាព ឯ.ឧ យ៉ុង គឹមហ៊ាន សមាជិកក្រុមប្រឹក្សាខេត្ត និងជានាយកសាខាកាកបាទ ក្រហមខេត្ត ដោយមានការអញ្ជើញចូលរួម÷ ពីប្រធាន កម្មវិធីអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន របស់កាកបាទក្រហម តំណាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត តំណាងអាជ្ញាធរ ស្រុក ឃុំ និង ប្រជាពលរដ្ឋសរុបប្រមាណ ៨០នាក់ ស្រី ២៨នាក់។

### 3. ការងារថែទាំសុខភាពជនបទ

- នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥ នៅសាលប្រជុំមន្ទីរ បានបើកកិច្ចប្រជុំស្តីពីការរៀបចំកសាង ផែនការសកម្មភាពលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ឆ្នាំ២០១៤-២០១៨ សម្រាប់ខេត្តក្រោមការដឹកនាំពីលោកបណ្ឌិត ដោក ដូម៉ា មន្ត្រីសម្របសម្រួលខេត្ត ។ អញ្ជើញ ចូលរួម÷លោកប្រធាន-អនុប្រធានមន្ទីរ ប្រធានការិ. និងមន្ត្រីសរុបចំនួន១៤នាក់ ក្នុងនោះស្រី ០២នាក់

- ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៥ ចូលរួមប្រជុំបច្ចេកទេសសុខាភិបាលខេត្តនៅមន្ទីរសុខាភិបាលខេត្តព្រះវិហារ។

4. **ការងារបណ្តុះបណ្តាល និង ស្រាវជ្រាវ ÷**
   - គ្មានសកម្មភាព។
5. **ការងារអភិវឌ្ឍន៍សហគមន៍÷**
   - គ្មានសកម្មភាព។
6. **ការងារសេដ្ឋកិច្ចជនបទ÷**
   - គ្មានសកម្មភាព។
7. **ការងារជនជាតិដើមភាគតិច÷**
   - នៅថ្ងៃទី ០៣-០៨ ខែមេសា ឆ្នាំ ២០១៥ បានចូលរួមផ្សព្វផ្សាយស្តីពីគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច វាយតម្លៃស្វ័យអត្តសញ្ញាណជនជាតិដើមភាគតិច និងនិតិវិធីនៃការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច នៅក្នុងភូមិឪឡឹក ឃុំរំដោះ ស្រុករវៀង អ្នកចូលរួមចំនួន ១១០នាក់ ស្រីចំនួន ៧៩នាក់ ភូមិព្រាល ឃុំរក្សា ស្រុករវៀង អ្នកចូលរួមចំនួន ៩៣នាក់ ស្រីចំនួន ៥៧នាក់ ភូមិដូនម៉ា ឃុំរក្សា ស្រុករវៀង អ្នកចូលរួមចំនួន ១០៦នាក់ ស្រីចំនួន ៧៥នាក់ និងនៅភូមិក្រឡាពាស ឃុំព្រីងធំ ស្រុកជាំក្សាន្ត អ្នកចូលរួមចំនួន ៩៨នាក់ ស្រីចំនួន ៤៥នាក់។ អ្នកចូលរួមសរុបចំនួន ៤០៧នាក់ ស្រីចំនួន ២៥៦នាក់។ វគ្គផ្សព្វផ្សាយនេះក្រោមការសម្របសម្រួលពីអាជ្ញាធរស្រុក ឃុំ និងពីមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រោមការឧបត្ថម្ភពីអង្គការពន្លកខ្មែរខេត្តព្រះវិហារ។
8. **ការងារយេនឌ័រ÷**
   - ថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៥ ចូលរួមកិច្ចប្រជុំលើកទី ៨ របស់គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ។
9. **ការងារ NGOs÷**
   - នៅថ្ងៃទី ០៦-០៧ ខែ មិនា ឆ្នាំ ២០១៥ បានសម្របសម្រួលវគ្គបណ្តុះបណ្តាលដល់នាយកសាលា លោកគ្រូ អ្នកគ្រូស្តីពីភាពជាម្ចាស់ការនៃការលើកកម្ពស់អនាម័យសុខភាពនៅថ្នាក់សាលារៀន នៅសាលាប្រជុំខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តដែលមានអ្នកចូលរួមសរុប ៦៤នាក់ ស្ត្រី ២៨នាក់ ដោយមានការគាំទ្រពីអង្គការទស្សនៈពិភពលោកប្រចាំខេត្ត។
   - ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៥ ចូលរួមក្នុងពិធីអបអរសាទរបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែររៀបចំឡើងដោយអង្គការទស្សនៈពិភពលោកប្រចាំខេត្តព្រះវិហារ
10. **គម្រោង / កម្មវិធី ÷**

10.1. **គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញទានបន្ថែម** (ADB)

- ថ្ងៃទី ០១-០៣ ខែមេសា ឆ្នាំ២០១៥ ចុះត្រួតពិនិត្យក្រាលក្រួសក្រហម ០១ខ្សែ ប្រវែង ៨.៣២២ម៉ែត្រ និង សំណង់ សិល្បៈការចំនួន ១១កន្លែង ក្នុងនោះលូប្រអប់ចំនួន ០២កន្លែង លូប្រអប់មុខ ៣ ០១កន្លែង លូមូលមុខពីរ ០៣កន្លែង និងលូទោលចំនួន ០៥កន្លែង នៅឃុំពោធិ ស្រុកត្បែងមានជ័យ ។ លទ្ធផលសម្រេចបានក្រុមហ៊ុនបានក្រាលក្រួសក្រហម បានប្រវែង ៨គ.ម សាងសង់លូប្រអប់ចំនួន ០១កន្លែង (៣មx៣មx៦ម) អនុវត្តបាន ៨០%
- ថ្ងៃទី ០៨-១០ ខែមេសា ឆ្នាំ ២០១៥ ចុះត្រួតពិនិត្យក្រាលក្រួសក្រហម ០១ខ្សែ ប្រវែង៨.៣២២ម៉ែត្រ និង សំណង់ សិល្បៈការចំនួន ១១កន្លែង ក្នុងនោះលូប្រអប់ចំនួន ០២កន្លែង លូទ្រីប០១កន្លែង លូភ្លោះ០៣កន្លែង និងលូទោលចំនួន ០៥កន្លែង នៅឃុំពោធិ ស្រុកត្បែងមានជ័យ។ លទ្ធផលសម្រេចបានក្រុមហ៊ុនបានក្រាលក្រួសក្រហមបានប្រវែង ៨.៣២២ម ស្មើនឹង១០០% សាងសង់លូប្រអប់ចំនួន ០១កន្លែង (៣មx៣មx៦ម) អនុវត្តបាន៩០%
- ថ្ងៃទី ១៦-១៨ ខែមីនា ឆ្នាំ២០១៤ ចុះត្រួតពិនិត្យក្រាលក្រួសក្រហម ០១ខ្សែ ប្រវែង ៨.៣២២ម៉ែត្រ និងសំណង់សិល្បៈការចំនួន ១១កន្លែង ក្នុងនោះលូប្រអប់ ចំនួន ០២កន្លែង លូទ្រីប ០១កន្លែង លូភ្លោះ ០៣កន្លែង និង លូទោលចំនួន០៥កន្លែង។ លទ្ធផលសម្រេចបាន ក្រាលក្រួសក្រហមបានប្រវែង ៥គ.ម អ្នកទទួលការលើកតួផ្លូវបានប្រវែង ៨.៣២២ម និង សាងសង់ លូប្រអប់ចំនួន ០១ កន្លែងអនុវត្តបាន ៧០%
- ថ្ងៃទី ១៩-២០ ខែមីនា ឆ្នាំ២០១៤ មន្ត្រីការងារខេត្ត PPMU និងមន្ត្រី CPMU ដឹកនាំដោយ លោក Biranchi Kuma Choudhury ប្រធានក្រុមជំនាញការADB ចុះត្រួតពិនិត្យការ និង ប្រគល់ទទួលផ្លូវក្រាលក្រួសក្រហម បញ្ចប់សុពលភាពរយៈពេល ០៦ខែ ចំនួន ០៤ខ្សែ ប្រវែង ២២.៨០៧ ម៉ែត្រ នៅឃុំពុទ្រា ស្រុកជ័យសែន ឃុំគួ លែនជើង ស្រុកគូលែន និងឃុំយាង ស្រុកជាំក្សាន្ត
- ថ្ងៃទី ២៤-២៦ ខែមីនា ឆ្នាំ២០១៤ ចុះត្រួតពិនិត្យក្រាលក្រួសក្រហម ០១ខ្សែ ប្រវែង ៨.៣២២ម៉ែត្រ និងសំណង់សិល្បៈការចំនួន ១១កន្លែង ក្នុងនោះលូប្រអប់ចំនួន ០២កន្លែង លូទ្រីប ០១កន្លែង លូភ្លោះ ០៣កន្លែង និងលូទោលចំនួន០៥កន្លែង។ លទ្ធផលសម្រេចបាន ក្រាលក្រួសក្រហម បានប្រវែង ៧គ.ម អ្នកទទួលការលើក តួផ្លូវបានប្រវែង ៨.៣២២ម និង សាងសង់លូប្រអប់ចំនួន ០១ កន្លែងអនុវត្តបាន ៧០%៕